# ការសំភាសន៍របស់បងប្រុស ច្រឹង ច្រួង

ក៖ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ារ ខ៖ អ្នកដែរអោយគេសំភាសន៍ ច្រឹង ច្រួង

## ការសង្ខេបប្រវត្តិរបស់ បងប្រុស ច្រឹង ច្រួង

បងប្រុស ច្រឹង ច្រួង មានអាយុ បងប្រុស ច្រឹង ច្រួង មានភេទប្រុស បងប្រុស ច្រឹង ច្រួង មានទីលំនៅបច្ចុប្បន្ននៅ ភូមិស្ទឹងជ្រៅ ឃុំផ្សារដើមមាន ស្រុកតាខ្មៅ ខេត្តកណ្ដាល។

ក៖ ចឹងជាដំបូងខ្ញុំអរគុណបងដែរបានអោយខ្ញុំពិភាក្សាពីប្រវត្តិរបស់បង ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរ មានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗៗពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយនឹងប្រវត្តិរបស់ជូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍បង ហើយនឹងដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗៗបានដឹងចឹងហាសបង ខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់បងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេបង?

ខ៖ បាទ!!ព្រមតើ!!

ក៖ បាទបងបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍បងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរ ខ្ញុំបានសំភាសន៍បងគឺនៅថ្ងៃទី5ខែ4 ឆ្នាំ2018 ហើយធ្វើនៅភូមិអីគេដែរបងភូមិអូរជ្រៅហីបង?

ខ៖ នៅភូមិស្ទឹងជ្រៅ

ក៖ ភូមិស្ទឹងជ្រៅ ចុះឃុំវិញបង?

ខ៖ ឃុំផ្សារដើមមាន ស្រុកតាខ្មៅ

កៈ នៅស្រុកតាខ្មៅនៅ ខេត្តកណ្តាលណាបង?

ខៈ បាទៗៗ!!នឹងហើយ

កៈ បាទ ចុះឈ្មោះពេញរបស់បងនឹងមានឈ្មោះអីគេដែរបង?

ខៈ មានឈ្មោះច្រួង

កៈ មានឈ្មោះអីគេដែរច្រួងបង?

ខៈ មានឈ្មោះច្រឹង ច្រួង

កៈ មានឈ្មោះច្រឹង ច្រួងណាបង?

ខៈ បាទនឹងហើយចឹង

កៈ បាទចឹងមានឈ្មោះហៅក្រៅដែរទេបង?

ខៈ អត់ទេមានឈ្មោះតែមួយនឹង

កៈ ចុះធ្លាប់មាននរណាគេហៅឈ្មោះបងអីទេពីមុនកាលបងនៅក្មេងៗហាស?

ខៈ អត់មានទេមានតែមួយនឹង

កៈ អត់ទេណាបងចុះបងសព្វថ្ងៃនឹងបងអាយុប៉ុន្មានដែរបង?

ខៈ ខ្ញុំមានអាយុ38ឆ្នាំនឹង

កៈ ចឹងបងអាយុ38ឆ្នាំ ចុះបងកើតនៅថ្ងៃខែឆ្នាំណាដែរបងមានចងចាំទេបង?

ខៈ ខ្ញុំអត់ចងចាំទេនៅក្នុងអត្តសញ្ញាណប័ណបានមាន

កៈ អ៊ូ!!បាទបងបាទ ចឹងសំរាប់ថ្ងៃខែក៏បងអត់មានចងចាំដែរណាបង?

ខៈ បាទបាទនឹងហើយ

កៈ ចឹងបងកើតនៅឆ្នាំ1980ហាសបង?

ខៈ នឹងហើយចឹង

កៈ ចុះសំរាប់បងកើតនៅភូមិអីឃុំអីបងមានចងចាំទេបង?

ខ៖ ខ្ញុំកើតនៅភូមិត្នោតញីហោស នៅភូមិត្នោតញី ឃុំខ្នុក

ក៖ ចឹងប៉ុន្តែនៅស្រុកអីគេដែរបង?

ខ៖ នៅស្រុកស្អាង

ក៖ នៅខេត្តកណ្តាលនឹងហោសបង?

ខ៖ បាទនៅស្រុកស្អាង ខេត្តកណ្តាលនឹងហាស

ក៖ ចុះសំរាប់បងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរបង?

ខ៖ ខ្ញុំមានបងប្អូនចំនួន9នាក់នឹង

ក៖ អូ៎!!មានច្រើនហាសណាបង?

ខ៖ បាទមានច្រើនណាស់មាន9នាក់នឹងហាស

ក៖ ចុះបងជាកូនទីប៉ុន្មានដែរបង?

ខ៖ ខ្ញុំជាកូនទី2នឹងហាស

ក៖ អូ៎!!បាទបង ចុះប្អូនៗៗនឹងបងៗៗរបស់បងនឹងមានឈ្មោះអីគេខ្លះដែរបងមានចងចាំទេបង?

ខ៖ ខ្ញុំចងចាំតើហើយយកឈ្មោះរបស់គាត់ទាំងអស់ទៀតនឹង

ក៖ បាទដោយសារតែយើងចង់ដឹងពីប្រវត្តិរបស់បង បងប្អូនរបស់បង នឹងឪពុកម្តាយរបស់បងចឹងហាសបង?

ខ៖ បាទចឹងហោស

ក៖ ចុះគាត់មានឈ្មោះអីកេដែរបង?

ខ៖ បងទី1នឹងមានឈ្មោះច្រាំ

ក៖ ចុះបន្ទាប់មកបានបង?

ខ៖ ខ្ញុំឈ្មោះច្រូង ទី2ឈ្មោះរុធ

កៈ នឹងទី3ហីបង?

ខៈ នឹងហើយទី3នឹងឈ្មោះវុធ ទី4នឹងឈ្មោះខាល ទី5នឹងឈ្មោះស្រី ទី6នឹងឈ្មោះសុខលី ទី7នឹងឈ្មោះចាន់សុខ ទី8ឈ្មោះចាន់ថា ទី9ឈ្មោះចាន់ធី

កៈ អូ!!ពៅគេហោសបង?

ខៈ នឹងហើយពៅគេនឹងឈ្មោះចាន់ធីប្រុស

កៈ
បាទបងចុះបងមានចងចាំងនុស្សាវរីយ៍អីកាលពីបងនៅក្មេងជាមួយបងប្អូនរបស់បងហាស ថាធ្លាប់បានលេងអីជាមួយគ្នាដែរទេ?

ខៈ ខ្ញុំធ្លាប់ដែរប៉ុន្តែវាភ្លេចអស់ហើយនឹង

កៈ ប៉ុន្តែលក្ខណៈថាលេងឡឹកបាយឡ លេងបិទពួនអីដែរតើហីអុំ?

ខៈ បាទលេងដែរនឹងលេងដែរប៉ុន្តែកាលនៅតូចៗនឹងយើង

កៈ មានភ្លេចខ្លះហើយណបង?

ខៈ មានភ្លេចដែរហើយនឹងហាស

កៈ ប៉ុន្តែដូចជាធ្លាប់ទៅស្រែអីជាមួយគ្នាដែរតើហីបង?

ខៈ ធ្លាប់ដែរតើទៅស្រែអីនឹង

កៈ លក្ខណៈថាចាប់ត្រី ចាប់ក្តាមអីចឹង?

ខៈ យើងទៅបឹងទៅអីនឹងទៅរកត្រីអីនឹងទៅដែរតើនឹងធ្វើស្រែធ្វើស្រូវអីនឹង

កៈ ប៉ុន្តែភាគច្រើនបងចូលចិត្តលេងអីគេដែរជាមួយពួកគាត់ចឹងហាសបង?

ខៈ ភាគច្រើនលេងធម្មតានឹងលេងមិនដឹងថាលេងអីគេខ្លះទេវាភ្លេចដែរហើយនឹង

កៈ អូ!!បាទបងបាទ?

ខៈ នៅក្មេងៗនឹងអីធម្មតាដូចយើងលេងពេលក្មេងៗឥឡូវនឹងហាស

កៈ អូ!!បាទបងបាទ ចុះប្អូនរបស់បងនឹងបងរបស់បងនឹងសព្វថ្ងៃគាត់នៅណាដែរបង?

ខ៖  គាត់រស់នៅស្រុកនឹងហាស

ក៖  គាត់នៅស្រុកទាំងអស់គ្នាតែម្តងនឹងហោសបង?

ខ៖  បាទនៅណុងស្រុកទាំងអស់គ្នានមឹងហាស

ក៖  ចុះពួកគាត់ធ្វើអីគេខ្លះដែរទៅបង?

ខ៖  គាត់ធ្វើការងារសំណង់ខ្លះចឹងទៅ អាបងគេធ្វើការងារសំណង់ចឹងទៅ អាប្អូនបន្ទាប់នឹងធ្វើការងារសំណង់ដែរនឹង

ក៖  ចុះប្អូនបន្ទាប់ៗៗទៀតនឹងពួកគាត់ធ្វើអីគេខ្លះដែរទៅបង?

ខ៖  បន្ទាប់ៗៗទៀតនឹងទៅធ្វើការនៅរោងចក្រទៅខ្លះទៅថៃទៅ ខ្ញុំទើបមកពីថៃនឹងហាស

ក៖  អូ៎!!ប៉ុន្តែពួកគាត់មិនទាន់មានគ្រួសារវីមួយក៏មានគ្រួសារអស់ហើយបង?

ខ៖  មានអស់ហើយនឹងនៅតែម្នាក់ទេនឹង

ក៖  នៅប្អូនពៅគេហោសបង?

ខ៖  បាទនឹងនៅពៅគេនឹងមួយនឹង

ក៖  អូ៎!!បាទបង ចុះឪពុករបស់បងនឹងគាត់មានឈ្មោះអីគេដែរបង?

ខ៖  គាត់មានឈ្មោះច្រឹង ឈ្មោះច្រឹង ច្រួងនឹង

ក៖  ចឹងមានឈ្មោះច្រឹង ច្រួង?

ខ៖  បាទខ្ញុំឈ្មោះច្រួង ឯគាត់វិញឈ្មោះច្រឹង

ក៖  អូ៎!!ឪពុករបស់បងហោសបង ?

ខ៖  បាទនឹងហើយចឹង

ក៖  ចុះសព្វថ្ងៃគាត់អាយុប៉ុន្មានដែរបង?

ខ៖  អាយុរបស់គាត់នឹងជិត60ឆ្នាំហើយខ្វះមួយឆ្នាំទៀតនឹង

ក៖  ប៉ុន្តែឥឡូវនឹងគាត់រស់នៅណាដែរទៅបង?

ខ៖ កាត់រស់នៅស្រុកនឹងហាស

ក៖ ចុះគាត់កើតនៅណាដែរបងមានដឹងទេ?

ខ៖ គាត់នៅស្រុកនឹងដែរនឹងកាត់នៅភូមិស្រុកជាមួយខ្ញុំណុងដែរនឹង

ក៖ អូ៎!!គាត់រស់នៅស្អាងនឹងហោសបង?

ខ៖ បាទគាត់នៅស្អាងដូចតែគ្នានឹងហាស

ក៖ ចុះម្ដាយរបស់បងនឹងគាត់មានឈ្មោះអីគេដែរបង?

ខ៖ ម៉ែរបស់ខ្ញុំនឹងមានឈ្មោះធឿន

ក៖ ប៉ុន្តែគាត់អាយុប៉ុន្មានដែរបង?

ខ៖ គាត់អាយុប្អូនពុកមួយឆ្នាំនឹងហាសគាត់ខុសត្រូវគ្នាមួយឆ្នាំនឹងហាស

ក៖ អូបាទបងដូចថាគាត់កើតនៅណាដែរម្ដាយរបស់បងហាស?
ខ៖ គាត់នៅជាមួយគ្នានឹងជាមួយម៉ែជាមួយឪនឹងនៅជិតគ្នានឹងហាសនៅភូមិជាមួយគ្នា

ក៖ បាទបងចុះឪពុករបស់បងកាលពីគាត់នៅកំលោះគាត់នៅដំបូងៗនឹង ពេលគាត់មានគ្រួសារដំបូងៗនឹងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតនឹងចិញ្ចឹមក្រុមគ្រួសារដែរបង?

ខ៖ គាត់ធ្វើស្រែ ប្អូននេសាទខាងនេសាទនឹង

ក៖ អូ៎!!ចឹងគាត់ធ្វើស្រែនឹងនេសាទណបង?

ខ៖ បាទនឹងហើយចឹងគាត់នេសាទនឹង

ក៖ ចុះឪពុករបស់បងនឹងគាត់កាចដែរទេបង?

ខ៖ គាត់អត់កាចទេធម្មតានឹងហាស

ក៖ អូ៎!!បាទបង ចុះម្ដាយរបស់បងវិញគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរបង?

ខ៖ ធ្វើជាមួយគ្នានឹងម្ដាយគាត់ធ្វើស្រែគាត់ដាំដំណាំអីចឹងទៅណាស់

ក៖ បាទបងបាទ?

ខ៖ កាលពីខ្ញុំនៅតូចៗៗនឹងគាត់រកស៊ីជួញដំឡូង ពោតទុកស្មោរលក់អីចឹងទៅណាស់

ក៖ អូ៎!!បាទបងបាទ ចុះម្តាយរបស់បងគាត់កាចរឺមួយក៏ស្លូតដែរបង?

ខ៖ គាត់មិនកាចប៉ុន្មានទេគាត់ស្លូតដែរនឹងហាស

ក៖ អូ៎!!ចឹងឪពុកម្តាយរបស់បងទាំងអស់នឹងគាត់ស្លូតដែរណាបង?

ខ៖ បាទនឹងហើយគាត់ស្លូតនឹង

ក៖ ចុះបងមានចងចាំថាកាលពីបងនៅជាមួយឪពុកម្តាយរបស់បងនឹងហាស
កាលពីបងមិនទាន់មានគ្រួសារហាសបងធ្លាប់ធ្វើអីគេខ្លះដែរទេបង?

ខ៖ ខ្ញុំធ្វើជាមួយគាត់ដែររកត្រីរកនេសាទជាមួយគ្នានឹងហាស

ក៖ អូ៎!!បាទនឹងជាអនុស្សាវរីយ៍ដែរបងនៅជាមួយគាត់ណាបង?

ខ៖ បាទនឹងហើយធ្វើស្រែអីចឹងទៅនឹងហាស

ក៖ អូ៎!!បាទបង
ចុះសំរាប់ឪពុករបស់បងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់ទៅបងដែរទេ?

ខ៖ អត់ទេអត់ដែរលឺគាត់និយាយអីផងនឹង

ក៖ ថាកាលពីមុនគាត់មានគ្រួសារគាត់ធ្លាប់ធ្វើអីគេខ្លះដែរចឹងទៅ
ហើយគាត់មុនគាត់មានទុកលំបាកអីគេខ្លះដែរនឹងគាត់មានដែរប្រាប់ទេ?

ខ៖ អត់ដែរប្រាប់និយាយអីទេនឹងហាស
គាត់ដែរតែនិយាយថាគាត់ពិបាកកាលពីជំនាន់ពលពតនឹងគាត់ពិបាកនឹងហើយគេធ្វើបាប
អីចឹងទៅណាស់វាចឹង

ក៖ អូ៎!!បាទបងបាទ?

ខ៖ បាទគាត់មានធ្លាប់និយាយអីចឹងដែរនឹង

ក៖ ចុះម្តាយរបស់បងវិញគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់ទេបង?

ខ៖ នឹងហើយម្តាយនឹងគាត់អ្នកប្រាប់ហោស

កៈ អ្ហ៎!!ចឹងហោសប៉ុន្តែគាត់មានប្រាប់អីគេខ្លះដែរទៅបង?

ខៈ
ខ្ញុំភ្លេចអស់ហើយគ្រាន់តែគាត់ប្រាប់ពីទុកលំបាកពីការរែកដីរែកអីនឹងហាសគាត់ធ្វើនៅទួលក្រសាំង

កៈ អ្ហ៎!!ចឹងទេហោសបង?

ខៈ គាត់រែកដីមិនអោយហូបបាយហូបអីចឹងទៅណាស់

កៈ ចឹងគាត់ធ្វើនៅទួលក្រសាំងនឹងហោសបង?

ខៈ នឹងហើយគាត់ធ្វើនៅទួលក្រសាំងនឹងទួលអីនឹង

កៈ អ្ហ៎!!បាទបង ចុះយាយតាខាង?

ខៈ
បាទហូបបបរមួយរែកៗអីចឹងទៅការងារគេអោយរែកដីទាំងយប់ទាំងប្រលប់ចឹងហាស

កៈ បាទបងបាទចឹង?

ខៈ គាត់និយាយប្រាប់កូនចឹង

កៈ បាទចុះយាយតាខាងឪពុកនឹងបងមានស្គាល់ឈ្មោះគាត់ដែរទេបង?

ខៈ ខ្ញុំស្គាល់ដែរតើ!យាយតាខាងឪពុកនឹងហាស

កៈ ចុះគាត់មានឈ្មោះអីគេដែរបង?

ខៈ ប៉ុន្តែគាត់បានស្លាប់អស់ហើយណាស់

កៈ បាទបងបាទ?

ខៈ គាត់មានឈ្មោះតាគ្រុយ នឹងយាយស៊ន

កៈ អ្ហ៎!!ចុះគាត់កើតនៅណាដែរបងមានដឹងទេ?

ខៈ តាគាត់កើតនៅស្អាងនឹងដែរនឹងនៅស្អាងព្រែកទូចយើងនឹង

កៈ ចុះយាយវិញបង?

ខ៖ យាយនៅបាលុនយើងនឹង

ក៖ មិញយាយខាងឪពុកណាបង?

ខ៖ បាទយាយខាងឪពុកនឹងហាស

ក៖ ចុះយាយតាខាងម្តាយវិញបង?

ខ៖ យាយតាខាងម្តាយនឹងខ្ញុំដឹងថាស្រុកកំណើតរបស់គាត់នឹងប៉ុន្តែអត់ដឹងថា
ខាងម្តាយនឹងគាត់មានឈ្មោះតាស្រឿង នឹងយាយយ៉ង់ហើយគាត់នៅជាមួយគ្នានឹង

ក៖ ប៉ុន្តែស្រុកកំណើតរបស់គាត់នឹងនៅណាដែរបងឯងមានដឹងអត់?

ខ៖ បើខ្ញុំដឹងនឹងមកនឹងគាត់នៅតែនឹងដែរនឹង

ក៖ អូ៎!!បាទបងបាទ?

ខ៖ គាត់នៅជាមួយគ្នានឹងហាស

ក៖ បាទបង ចុះបងមកនៅនឹងយូរនៅបង?

ខ៖ ខ្ញុំមកនៅនេះអស់10ឆ្នាំហើយនឹង

ក៖ អូ៎!!បាទបងបាទនឹង?

ខ៖ ខ្ញុំមកនៅជិត10ឆ្នាំហើយ
ខ្ញុំទៅថៃនឹងអស់4ឆ្នាំហើយមកពីថៃវិញនឹងទិញដីធ្វើផ្ទះនៅនឹង

ក៖ អូ៎!!ចឹងទេហោសបង?

ខ៖ បាទទៅថៃនោះអស់4-5ឆ្នាំហើយនឹង

ក៖ អូ៎!!បាទបងបាទ ចុះបងមានសាច់ញ្ញាតិរឺបងប្អូនណាដែររស់នៅក្រៅប្រទេសទេបង?

ខ៖ មានតែប្អូនប្រុសម្នាក់នឹងនៅកូរ៉េ ទៅកូរ៉េនឹងហាស

ក៖ អូ៎!!គាត់ទៅធ្វើការងារនៅកូរ៉េណាបង ចុះគាត់ធ្វើការងារអីគេដែរនៅកូនរ៉េនឹងហាសបង?

ខ៖ គាត់ធ្វើការងារនៅរោងចក្រនឹង

កៈ ប៉ុន្តែបងមានបងប្អូននៅថៃដែរទេបង នឹងវៀតណាមហាស?

ខៈ
នៅថៃយើងនៅវៀតណាមអត់មានទេនៅថៃមានពីរនាក់ប៉ុន្តែមកវិញហើយនឹងគាត់មកមុនចូលឆ្នាំនឹង

កៈ អូ៎!!បាទចុះឥឡូវនឹងគាត់នៅថៃនឹងរឺមួយនៅខ្មែរនឹងទេបង?

ខៈ គាត់បានមកខ្មែរវិញហើយនឹងហាស

កៈ អូ៎!!បាទបងបាទ?

ខៈ ប្អូនរបស់ខ្ញុំអាទី4នឹងហាស

កៈ បាទបងបាទ?

ខៈ គេមានគ្រួសារដែរនឹងមានកូនមួយហើយមួយទៀតនៅក្នុងពោះនឹង

កៈ បាតបងចុះសំរាប់ភរិយារបស់បងនឹងគាត់មានឈ្មោះអីគេដែរបង?

ខៈ ប្រពន្ធរបស់ខ្ញុំនឹងមានឈ្មោះចាន់ ស៊ី

កៈ ចុះបងមានចងចាំថ្ងៃខែដែរបងបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់ដែរទេ?

ខៈ ខ្ញុំអត់បានចងចាំទេ

កៈ ចុះសំរាប់ឆ្នាំវិញបងមានចងចាំទេ?

ខៈ ឆ្នាំនឹងគឺនៅឆ្នាំខាល

កៈ ចុះថ្ងៃដែរបងរៀបអាពាហ៍ពិពាហ៍នឹងបងមានចងចាំដែរទេថ្ងៃខែឆ្នាំណាចឹងហាស?

ខៈ ឆ្នាំនឹងដឹងតែចងចាំឆ្នាំខ្មែរយើងនឹងឆ្នាំបារាំងអត់មានចងចាំទេនឹងហាស

កៈ បាទបងប៉ុន្តែដូចជា?

ខៈ គេឆ្នាំខាលនឹងដូចជាអាយុ20ឆ្នាំជាងហើយនឹង

កៈ ប៉ុន្តែកូនប្រុសកូនបងរបស់បងនឹងឥឡូវនឹងអាយុប៉ុន្មានដែរបង?

ខ៖ កូននឹងអាយុ19ឆ្នាំហើយនឹង

ក៖ អូ៎!!ចឹងបងការអស់ជាង20ឆ្នាំហើយនឹងចឹងបង?

ខ៖ វាអាយុ19ឆ្នាំថ្មីហើយនឹងវាឆ្នាំថោះហាស

ក៖ អូ៎!!កាលពីបងការនឹងបងអាយុប៉ុន្មានដែរបង?

ខ៖ ខ្ញុំអាយុពេលណុងអាយុ18ឆ្នាំនឹង ហើយប្រពន្ធរបស់ខ្ញុំនឹងអាយុ16ឆ្នាំនឹង

ក៖ អូ៎!!ចឹងមានន័យថាដល់ឥឡូវនឹងវា20ឆ្នាំហើយណបង?

ខ៖ វាបាន20ឆ្នាំហើយនឹង

ក៖ អូ៎!!បាទបងបាទ ចុះបងគិតថានៅពេលដែរបងរៀបចំរៀបអាពាហ៍ពិពាហ៍នឹងគិតថាឪពុកម្តាយរបស់បងជាអ្នករៀបចំអោយរឺមួយក៏បងរៀបចំដោយចិត្តឯងដែរបង?

ខ៖ ឪពុកម្តាយជាអ្នករៀបចំអោយនឹង

ក៖ ប៉ុន្តែពេលណុងមានជាជំនូនជូនទៅប្រពន្ធរបស់បងអីទេបង
មានជាថ្លៃទឹកដោះអីហាស?

ខ៖ យើងពេលណុងមានតិចតួចដែរនឹងពេលណុងយើងអ្នកអត់ដូចគ្នាហាស

ក៖ អូ៎!!បាទបង ចុះហេតុអីបានជាបងពេញនឹងបងស្រី
ហើយបងស្រលាញ់គាត់ប៉ុន្មានឆ្នាំដែរបានបងចូលស្តីដណ្តឹងគាត់ចឹងហាសបង?

ខ៖ បានមួយឆ្នាំជាងនឹងពីរឆ្នាំនឹងហាស

ក៖ ប៉ុន្តែបងបានឃើញគ្នានៅពេលណាដែរទៅបង?

ខ៖ ពិបាកដែរឃើញគ្នាពិបាកនិយាយដែរនឹង

ក៖ អូ៎!!យើងនឹង?

ខ៖ ចេះតែដើរលេងចឹងទៅផ្ទះនៅជិតគ្នាដែរនឹង

ក៖ អូ៎!!មិនមែនបងទៅធ្វើការងារអីជាមួយគ្នារឺបងរៀនអីជាមួយគ្នាណាហីបង?

ខ៖ អត់ដែរទេអត់ដែររៀនអីជាមួយគ្នាផងនឹង

កៈ ប៉ុន្តែផ្ទះនៅជិតគ្នាណាបង?

ខៈ នឹងហើយផ្ទះនឹងនៅមួយគីឡូដីអីពីគ្នានឹងហាស

កៈ អូ៎!!បាទបងចុះបង?

ខៈ មិនដល់មួយគីឡូផងនឹងហាស

កៈ ចុះបងរៀនភាសាខ្មែរបានថ្នាក់ទីប៉ុន្មានដែរបង?

ខៈ ខ្ញុំអត់ដែរបានរៀនផងដូចថាគ្រួសារវារៀងដុនដាប់ពេកវារៀងពិបាកនឹងហាស

កៈ អូ៎!!ចឹងគ្មានពេលបានទៅរៀនទេហោសបង?

ខៈ បាទពួកគាត់ឈឺអីចឹងហើយបងៗៗក៏មានច្រើនចឹង
អាបងៗៗទី2នឹងគេបានរៀនប្អូនអីនឹងបានរៀន
គ្រប់គ្នាហើយខ្ញុំមិនបានរៀនទេជួយធ្វើស្រែធ្វើស្រូវអីចឹងហាស

កៈ អូ៎!!ដោយសារតែបងជាបងគេណោះបង?

ខៈ បាទខ្ញុំពីតូចនឹងបានចូលរៀនដែររៀនបានថ្នាក់ទី2នឹងប៉ុន្តែរៀនធ្លាក់
ឡើងចុងកន្ទួតដល់ពេលចឹង
បានធ្លាក់ទៅបាក់កជើងចឹងទៅអស់3ខែដល់ពេលចឹងលែងបានទៅរៀន
ហើយភ្លេចអក្សរភ្លេចអីចឹង

កៈ ប៉ុន្តែកាលពីបងរៀននឹងបងរៀននៅសាលាណាដែរបង?

ខៈ ខ្ញុំបាក់ជើង ខ្ញុំរៀននៅសាលាព្រៃទទឹងនឹង

កៈ រៀននៅព្រៃទទឹងនឹងខេត្តកណ្តាលយើងនឹង នៅស្អាងយើងនឹងហោសបង?

ខៈ បាទនៅស្អាងយើងនឹងហាស សាលាព្រៃទទឹងយើងហ៊ុនសែននឹង
ចុះដូចជាបងមានចេះភាសាអី ក្រៅពីភាសាខ្មែរដែរទេបង?

ខៈ អត់អត់ចេះទេ

កៈ ចុះភាសាអង់គ្លេស ថៃអីក៏បងអត់ចេះដែរ?

ខ៖ អត់ចេះទេនឹង ចុះបើអត់បានរៀនផងនឹង

ក៖ អូ៎!!ចឹងបានបង ចុះ?

ខ៖ នឹងហើយទៅថៃនឹងចេះមួយម៉ាត់ៗៗនឹងនិយាយតជាមួយថៃបានខ្លះស្ដាប់បាន

ក៖ អូ៎!!ចឹងមានន័យថាបងមានចេះថៃខ្លះៗៗមែនទេបង?

ខ៖ នឹងហើយចេះ

ក៖ ចុះបងគិតថាកាលពីបងនៅរៀននឹងបងធ្លាប់មានមិត្តភក្ដិដែរស្និទ្ធិស្នាល
នឹងធំធាត់មកជាមួយគ្នាដែរទេបងកាលនៅក្មេងៗៗហាសបងធ្លាប់មានមិត្តភក្ដិដែរធំធាត់
ហើយស្និទ្ធិស្នាលដែរទេបង?

ខ៖ មានតែមិត្តភក្ដិប្រុសៗៗឥឡូវនឹងវាបែកគ្នាឃ្លូរហើយវាលែងស្និទ្ធិស្នាលហើយនឹង

ក៖ អូ៎!!ដល់ពេលចឹង?

ខ៖ បែកគ្នានៅឆ្ងាយៗៗនៅបែកគ្នារៀងខ្លួនចឹងទៅវានៅឆ្ងាយៗៗ

ក៖ បាទប៉ុន្តែបង?

ខ៖ ប៉ុន្តែនៅរាប់អានគ្នាធម្មតាចឹងទៅណាស់

ក៖ ប៉ុន្តែបងនៅចងចាំឈ្មោះពួកគាត់ដែរទេបង?

ខ៖ ខ្ញុំនៅចងចាំដែរតើ!!

ក៖ ពួកគាត់មានឈ្មោះអីគេខ្លះដែរទៅបង?

ខ៖ យកឈ្មោះទាំងមិត្តភក្ដិប្រុសទៀត
មិត្តភក្ដិនឹងមានតែមិត្តភក្ដិប្រុសទេគ្មានមិត្តភក្ដិស្រីទេណាស់

ក៖ បាទនឹងមិត្តភក្ដិប្រុសៗៗនឹងដែរបងបានស្និទ្ធិស្នាលជាមួយគ្មានឹងហាសបង?

ខ៖ មានឈ្មោះតុង តង់អានឹងបងប្អូនវាសុទ្ធតែមិត្តភក្ដិ

ក៖ បាទបងបាទ ចុះប៉ុន្តែបងធ្លាប់មានអនុស្សាវរីយ៍អីជាមួយគ្នាដែរបងគិតថា
ទៅស្រែជាមួយគ្នាបងចងចាំអត់ភ្លេចចឹងហាសបង?

ខ៖ បាទមានឈ្មោះហ៊ុន ឈ្មោះហាក់អីនឹង មិត្តភក្តិមាន3-4នាក់នឹងហាស

ក៖ ប៉ុន្តែបងធ្លាប់មានអនុស្សាវរីយ៍អីជាមួយគ្នាដែរទេបង?

ខ៖
ដូចជាគ្មានអនុស្សាវរីយ៍អីទេគ្រាន់តែមានអនុស្សាវរីយ៍អីដើរលេងជាមួយគ្នាធម្មតានឹងហាស

ក៖ អូ៎!!ចឹងទេហោសបង?

ខ៖ ហើយនឹងយប់ព្រលប់អីធម្មតានឹង

ក៖ អូ៎!!ចឹងណាបង?

ខ៖ នឹងហើយគ្មានអនុស្សាវរីយ៍អីច្រើនទេអត់មាន

ក៖
ចុះបងគិតថាបងធ្លាប់ធ្វើការងារអីគេខ្លះដែរបងតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង?

ខ៖ ការងារធ្វើច្រើនមុខហាសធ្វើសំណង់ក៏ធ្លាប់
ធ្វើថារកស៊ីខ្លួនឯងចឹងទៅលក់ការ៉េមលក់អីចឹង លក់អីក៏ធ្លាប់ដែរនឹង

ក៖ អូ៎ៗៗ!!ចឹង?

ខ៖ នឹងហើយរកស៊ីលក់ការ៉េម លក់នំប៉័ងអីនឹងរកស៊ី

ក៖ ចឹងបងធ្វើការងារច្រើនដែរចឹង?

ខ៖ បាទទៅថៃទភៅអីចឹងមានច្រើនមុខណាស់ ស៊ីឈ្នួលគេមួយចប់
បើខាងធ្វើស្រែវិញស៊ីឈ្នួលធ្វើស្រែ ធ្វើអីចឹងទៅ

ក៖ អូ៎!!ចឹងមានន័យថាបងធ្លាប់ធ្វើស្រែចំការដែរណាបង?

ខ៖ ធ្វើស្រែចឹងធ្វើស្រូវយើងធ្វើខ្លួនឯងហើយបានយើងស៊ីឈ្នួលគេទៀតនឹង

ក៖ អូ៎!!បាទបងបាទ?

ខ៖  មុនដំបូងពីធ្វើមុននឹងមានម៉ាស៊ីនបោកម៉ាស៊ីនអីដូចឥឡូវនឹងណា ពីមុននឹងសុទ្ធតែប្រើដៃបោកដៃនឹង

ក៖  បាទបងបាទ?

ខ៖  ចងកណ្ដាប់ចងអីនឹងច្រូត យើងច្រូតដៃនឹង

ក៖  បាទៗបងបាទចុះ?

ខ៖  ធ្វើស្រែភ្ជួររាស់អីនឹងហាស

ក៖  ចុះបងគិតថាបងធ្លាប់បើកអាជីវកម្មលក់ដូរអីទេបង?

ខ៖  ចង់បើកដែរប៉ុន្តែយើងអត់មានដើមទុនធំចឹងយើងបើកលក់អោយគ្នាឯងតិចតួចនឹង

ក៖  ប៉ុន្តែឥឡូវនឹងបងលក់ឥវ៉ាន់ចាប់ហ្វូយណាបង?

ខ៖  បាទលក់ឥវ៉ាន់ចាប់ហ្វូយនឹងវាខ្វះដើមដែរមានតិចតួចគ្នាឯងចឹងទៅ

ក៖  ចុះបងមានធ្លាប់ចិញ្ចឹមសត្វទេ ដូចជាចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូក ចិញ្ចឹមគោអីចឹងហាស?

ខ៖  ចិញ្ចឹមធ្លាប់ចិញ្ចឹមដែរប៉ុន្តែឥឡូវនឹងឈប់ចិញ្ចឹមហើយនឹង ប៉ុន្មានឆ្នាំមុននឹងចិញ្ចឹនជ្រូកចិញ្ចឹម មាន4ក្បាលទៅ10ក្បាលអីនឹងហាសចិញ្ចឹមនៅក្រោមផ្ទះនឹងប៉ុន្តែឥឡូវនឹងឈប់ហើយ មានចិញ្ចឹមជ្រូក ចិញ្ចឹមគោប៉ុន្តែឥឡូវនឹងលក់អស់វិញហើយគោអីនឹង

ក៖  ប៉ុន្តែមាន់ ទាអីបងមានដែរចិញ្ចឹមទេ?

ខ៖

មាន់នឹងយើងចិញ្ចឹមរាល់តែថ្ងៃនឹងប៉ុន្តែយើងចិញ្ចឹមតិចតួចនឹងវាមិនបានលក់មិនបានដូរទេ គ្រាន់តែ

ក៖  បានតែទុកហូបខ្លួនឯងហោសបង?

ខ៖  បាទគ្រាន់វាបានទុកហូបខ្លួនឯងនឹងហាស

ក៖  អូ!!បាទបង ចុះបងគិតថាជីវិតរបស់បងមានការផ្លាស់ប្ដូរអីគេដែរ
តាំងពីក្មេងរហូតមកដល់ពេលនេះហាសបង?

ខ៖
ដូចជាអត់មានការផ្លាស់ប្ដូរអីប៉ុន្មានទេគ្រាន់តែវាពីមុនមកកន្លងមកនឹងជីវភាពរៀងដុនដាប់ដែរនឹង កូននៅតូចៗឥឡូវនឹងកូនវារៀងធំៗអស់ហើយនឹងវាគ្រាន់បន្តិចនឹង

ក៖  អូ!!បានធូរដៃធូរជើងហោសបង?

ខ៖  បាទបានធូរដៃធូរជើងនឹងហាស
ស្រួលត្រង់ថាចេញទៅរកស៊ីនៅណាក៏កូននៅមើលផ្ទះមើលអីចឹងទៅ

ក៖  បាទបងបាទ ចុះបងគិតថាម្ហូបអីគេដែរបងចូលចិត្តពិសារបង?

ខ៖  ម្ហូបអីនឹងធម្មតានឹងម្ហូបខ្មែរយើងនឹង សម្លខ្មែរយើងធម្មតានឹងហាស

ក៖  លក្ខណះដូចជា?

ខ៖  លក្ខណះដូចជាស្លប្រហើរអីចឹងទៅណាស់ កកូរ ចៀនអីនឹងចឹង

ក៖  នឹងដែរបងចូលចិត្តណាបង
ចុះកាលពីនៅក្មេងនឹងបងចូលចិត្តលេងល្បែងប្រជាប្រិយ៍អីទេបង?

ខ៖  លេងដែរលេងប្រជាប្រិយ៍លេង

ក៖  លេងចោលឈូង បោះអង្គុញ?

ខ៖  ចោលឈូង បោះអង្គុញ លាក់កន្សែងអីនឹង

ក៖  មានទាញព្រាត់អីនឹងហោសបង?

ខ៖  ទាញព្រាត់អីនឹងហាស

ក៖  ប៉ុន្តែភាគច្រើននឹងបងលេងនៅណាដែរបង?

ខ៖  ភាគច្រើននឹងលេងនៅពេលមានបុណ្យទាននឹងរដូវចូលឆ្នាំអីលេងអានឹងហោស
លេងតាមវត្តនឹង

ក៖ លេងនៅស្រុកនឹងហោសបង?

ខ៖ បាទលេងនៅស្រុក លេងតាមវត្តនៅស្រុកអីចឹងទៅណាស់

ក៖ អូ៎!!បាទប៉ុន្តែបងចេះច្រៀងដែរទេបង?

ខ៖ អូ៎!!អត់ចេះច្រៀងផងនឹង ចេះតែច្រៀងលេងម្នាក់ឯងធម្មតាចឹងទៅ ចេះតែច្រៀងៗទៅ

ក៖ ប៉ុន្តែបងចូលចិត្តស្ដាប់បទចំរៀងដែរទេបង?

ខ៖ ខ្ញុំចូលចិត្តស្ដាប់ដែរតើនឹង

ក៖ តើបទសម័យរឺមួយក៏បទបុរាណដែរបងចូលចិត្តស្ដាប់ហាសបង?

ខ៖ បទបុរាណបទស៊ិនស៊ីសាម៉ុតនឹង កែវសារ៉ាត់

ក៖ អូ៎!!បាទបងបាទ ចុះបងចូលចិត្តស្ដាប់ល្ខោនយីកេអាយៃអីទេបង?

ខ៖ ដូចជាអត់សូវចំណូលដែរល្ខោន យីកេនឹង

ក៖ អូ៎!!បាទចុះបងគិតថាមាននរណាគេម្នាក់នៅក្នុងក្រុមគ្រួសាររបស់បងចេះលេងឧបករណ៍ភ្លេងដែរទេ?

ខ៖ អត់មានផងបងក្រុមគ្រួសាររបស់ខ្ញុំនឹងអត់ដែរមានអ្នកចេះលេងភ្លេងផងនឹងអត់មានទេ

ក៖ អូ៎!!លក្ខណះភ្លេងសម័យ ភ្លេងបុរាណអីក៏អតចេះដែរណាបង?

ខ៖ បាទអត់អត់មានទេ

ក៖ ចុះផ្ទះរបស់បងនឹងមានលក្ខណះបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង?

ខ៖ ពីក្មេងមកនឹងផ្ទះតូចធម្មតាល្មមនឹងចឹងទៅ ដល់ពេលឥឡូវនឹងជីវភាពយើងរកបានទៅគ្រាន់បាន ធ្វើផ្ទះតៗទៀតចឹងទៅ

កៈ ធ្វើវារៀងគួរសមចឹងទៅណាបង?

ខៈ បាទនឹងហើយចឹង

កៈ ចុះផ្ទះទាំងអស់នឹងបងជាអ្នកសាងសងតែម្តងហោសបង?

ខៈ ដូចជាផ្ទះយើងជួលគេធ្វើនឹង

កៈ បងជួលគេធ្វើណាបង បងអត់ចេះធ្វើផ្ទះទេណាបង?

ខៈ យើងជួលឈ្នួលជាងគេធ្វើទៅនឹងហើយយើងអោយលុយគេទៅនឹង

កៈ ប៉ុន្តែបងចេះធ្វើផ្ទះដែរទេ?

ខៈ ផ្ទះនឹងចេះធ្វើដែរធ្លាប់បានធ្វើខ្លួនឯងនឹងផ្ទះលក្ខណះធម្មតាចឹងទៅ
ដូចថាផ្ទះធំជុំផ្ទះម្តាយឪពុកចឹង យើងជួលជាងធ្វើថ្មីចឹងទៅ

កៈ អូ៎!!បាទបងបាទ ប៉ុន្តែនរណាគេដែរបង្រៀនបងអោយចេះធ្វើផ្ទះហាសបង?

ខៈ អត់មានអ្នកបង្រៀនផងនឹង

កៈ ចឹងបងចេះមកពីនរណាគេដែរបង?

ខៈ ខ្ញុំចេះដោយគំនិតខ្លួនឯងនឹងហាស កែច្នៃធ្វើខ្លួនឯងនឹង

កៈ ចឹងបងមើលគេធ្វើទៅណាបង?

ខៈ បាទយើងមើលគេធ្វើនឹងហាស

កៈ អូ៎!!បាទបង ចុះផ្ទះរបស់បងនឹងគេធ្វើឧបករណ៍អីគេខ្លះដែរ
សំរាប់សាងសងដូចជាមានសំភារះអីគេខ្លះដែរចឹងហាស?

ខៈ សំភារះធ្វើហោសបើផ្ទះឈើនឹងមានរណា ពូថៅ មានដែកគោលដែកអីនឹងហាស
ទុកដំធ្វើជារនាប ជាក្តារអីចឹងទៅណាស់

កៈ បាទបងបាទ?

ខៈ មានប្រើដែកគោលមានប្រើអីចឹងទៅ

កៈ ចុះបងគិតថាជំនាញអីគេដែរបងចេះស្ទាត់ជំនាញហាសបង?

ខ៖ អត់មានអត់អតមានជំនាញស្នាត់អីទេអោយប្រាកដប្រជាទេសព្វថ្ងៃនឹង
ដូចជារកបានធម្មតាចឹងទៅរកសអីបានរកនឹងចឹងទៅ

ក៖ អូ៎ៗ!!ចឹងហោសបង?
ខ៖ រកនេសាទបានរកនេសាទចឹង
បើថាអោយទៅរកមុខជំនាញធ្វើការស៊ីឈ្នួលគេដូចមិញនឹងអត់មានទេ

ក៖ បងអត់មានអីជាច្បាស់លាស់ប៉ុន្តែបងចេះធ្វើទាំងអស់ណាបងមានតិចតួចៗអីចឹងទៅ?

ខ៖ នឹងយើងវាចេះតិចតួចយើងមិនមានអីចេះប្រាកដធំទេ

ក៖ ចុះដូចជាឪពុកម្ដាយរបស់បងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅបងដែរទេ?

ខ៖ អត់មានទេ

ក៖ ចឹងអត់មានទេណាបង?

ខ៖ មានតែនៅជាមួយគាត់នឹងមានតែជំនាញធ្វើស្រែធ្វើស្រូវនឹង
ជំនាញធ្វើស្រែធ្វើស្រូវហើយ រកត្រីអីចឹងទៅណាស់

ក៖ ចុះលក្ខណះថា កូរស្ករត្នោត ធ្វើផ្ដៅ ធ្វើកន្ទេល ធ្វើអីនឹងបងមានចេះអត់?

ខ៖ អត់មានទេនឹងស្ករត្នោតនឹងពុកគាត់ធ្លាប់ធ្វើ ប៉ុន្តែខ្ញុំអត់ចេះទេ

ក៖ អូ៎!!ចឹងហោសបង?

ខ៖ គាត់ធ្វើតាំងពីខ្ញុំនៅតូចៗប៉ុនៗនេះមកនឹងគាត់ឡើងត្នោតនឹង

ក៖ បាទប៉ុន្តែបងអត់ចេះទេណាបង?

ខ៖ បាទខ្ញុំអត់ចេះទេនឹង

ក៖ អូ៎!!បាទបង ចុះ?

ខ៖ គាត់ចេះឡើងត្នោតទៀតនឹង

ក៖ អូ៎!!ប៉ុន្តែបងចេះឡើងត្នោតដែរទេបង?

ខ៖ ឡើងខ្ញុំចេះដែរតើ ប៉ុន្តែគ្រាន់តែខ្ញុំអត់ចេះធ្វើស្ករនឹង

ក៖ អូ!!ចឹងទេ?

ខ៖ ដូង ត្នោតអីនឹងខ្ញុំធ្លាប់ឡើងកាលពីមុនខ្ញុំទៅធ្វើការងារនៅចំការធុរ៉េននៅកំពត់ហោស កាលកូនពីរនឹងនៅតូចៗៗនឹងនៅចាំដូងគេមួយថ្ងៃគេអោយឡើងដូងគេមួយថ្ងៃនឹងអស់10-20ដើមនឹង

ក៖ អូ!!បងឡើងដូងបានដែរហោសបង?

ខ៖ ឡើងដូងកាប់ធាង យកមកដាំធុរ៉េននឹងហាស

ក៖ ប៉ុន្តែកាលណុងបងនៅក្មេងៗៗដែរទេ?

ខ៖ ខ្ញុំនៅអាយុ25ឆ្នាំអីនឹងហាស

ក៖ អូ!!បាទបងបាទ?

ខ៖ នៅអាយុ24-25ឆ្នាំអីនឹងហាសកាលកូននៅតូចៗៗនឹង

ក៖ បាទចុះបងធ្លាប់ជួបកាលលំបាកអីគេដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង កាលពីក្មេងនឹងបងធ្លាប់មានការលំបាកអីគេខ្លះដែរទៅ?

ខ៖
លំបាកខ្លាំងនឹងមានតែធាក់កង់ការ៉េមនឹងមួយថ្ងៃៗៗទល់ៗៗល្ងាចទៅទាំងភ្លៀងយប់អីមក នឹង ផ្លូវពិបាកផុកអីនឹងជួនកាលបណ្តើរកង់លីអីនឹង
ទុកទំលាក់ធុងការ៉េមកណ្តាលផ្លូវក៏មានដែរនឹង

ក៖ អូ!!បាទបងបាទ?

ខ៖ ស្រាយធុងមកអត់រួចចឹងទៅ

ក៖ អូ!!បាទបងបាទ?

ខ៖
ចុះជិះមានតាមភូមិមានផ្ទះអីចឹងកន្លែងខ្លះជិះដាច់ភូមិឆ្ងាយៗៗដាច់ច្រើនគីឡូដីអីចឹងទៅ ណាស់

ក៖ អូ៎!!ចឹងបាទបងបាទ?
ខ៖ ជិះកាត់ព្រៃកាត់ផ្សេងទៅពីភូមិមួយទៅភូមិមួយហាសខ្ញុំទៅឆ្ងាយៗៗណាស់

ក៖ អូ៎!!បងទៅឆ្ងាយៗៗដែរណបង?

ខ៖ ខ្ញុំទៅឆ្ងាយៗៗដែរនឹង

ក៖ នឹងកាលពីបងនៅតូចៗៗមែនទេបង?

ខ៖ ខ្ញុំនៅពេញរកនឹងពេញកំលោះហើយនឹង ពេលដែរមានប្រពន្ធនឹងក៏នៅតែរកចឹងដែរ

ក៖ ចុះកាលពីបងមានប្រពន្ធដំបូងៗៗនឹងបងមានការលំបាកអីគេខ្លះដែរបង?

ខ៖
វាគ្មានការលំបាកអីទេបានគ្នាទៅធ្វើស្រែធ្វើស្រូវធម្មតាចឹងទៅណាស់បាទធ្វើស្រូវបានចឹង

ក៖ ប៉ុន្តែកាលបងមានក្រុមគ្រួសារដំបូងនឹងបងនៅស្រុករឺមួយក៏នៅនឹងតែម្តងនឹងបង?

ខ៖ ខ្ញុំនៅស្រុកនឹង

ក៖ ចុះរហូតដល់ពេលណាដែរបងគិតថាបងផ្លាស់ទីលំនៅមកនៅនឹងដែរបង?

ខ៖ នៅស្រុកមកពីថៃហើយនឹង ទៅថៃបានបួនឆ្នាំបានផ្លាស់មកនៅនឹង

ក៖
ចុះបងមាននរណាគេអោយនាំបងមកនៅនឹងរឺមួយក៏បងមកនៅខ្លួនឯងដែរចឹងហាសបង?

ខ៖ មកតាមខ្សែរយះពីបងប្អូនម៉ែឪ ពីម៉ែក្មេកឪក្មេកគាត់មករកអីធ្វើស្រែអីនៅនឹងចឹងហាស

ក៖ អូ៎!!បាទបងបាទ?

ខ៖ មកនឹងចេះតែមកចឹងទៅសុទ្ធតែខាងពីស្រុកខ្ញុំទាំងអស់នឹង

ក៖ អូ៎!!អ្នកនៅម្តុំនឹងហោសបង?

ខ៖ បាទអ្នកនៅម្តុំនឹង

ក៖ អូ៎!!ល្អដែរ

ខ៖ យាយតាមីងមាខាងប្រពន្ធអីនឹងហាសវាមានច្រើននាក់ដែរនឹង

កៈ រហូតមកដល់ឥឡូវនឹងជីវភាពរបស់បងដល់ឥឡូវនឹងវាគួរសមហើយណាបង?

ខៈ បាទវាមធ្យមវាគ្រាន់បានចិញ្ចឹមកូនមួយរស់អីនឹង

កៈ ចង់និយាយលក្ខណៈថាវារស់ស្រួលហើយណាបង?

ខៈ បាទនឹងហើយ

កៈ
ចុះបងគិតថាបងឆ្លងកាត់ការលំបាកនេះខំប្រឹងប្រែងដោយរបៀបណាដែរបងជំនះឧបសគ្គហាស?

ខៈ ជំនះឧបសគ្គនឹងវាគ្មានឧបសគ្គអីធំដុំប៉ុន្មានទេ
យលងអាចស៊ូបានយើងអាចរកបានចិញ្ចឹមកូន មួយហូបចឹងហាស

កៈ បាទបងបាទ?

ខៈ ចង់និយាយថាយើងកាលពីក្មេងមកយើងមិនបានរៀនសូត្រមិនបានចេះដឹងទេ
ប៉ុន្តែគ្រាន់តែយើងអាចចិញ្ចឹមកូនចិញ្ចឹមអីបាន

កៈ អូ!!បាទបងបាទ?

ខៈ ខ្ញុំអាចរកស៊ីចិញ្ចឹមកូនបានដល់សព្វថ្ងៃនឹងហាស

កៈ
ចុះបងគិតថាពេលណាដែរបងគិតថាជាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់បងដែរទៅ?

ខៈ ពេលសប្បាយនឹងរាល់ថ្ងៃក៏អត់មានកើតទុកអីគេដែរ យើងសប្បាយធម្មតាធម្មមនឹង
ដូចគេដូចឯងចឹងដែរនឹង

កៈ អូ!!បាទចឹងហោសបង?

ខៈ បាទអត់មានពេលសប្បាយខ្លាំងក៏ពេលកើតទុកខ្លាំងនឹងក៏មិនសូវមានដែរ

កៈ ប៉ុន្តែដូចជា?

ខៈ វាធម្មតានឹងហាស

ក៖ ចុះពេលដែរបងរៀបអាពាហ៍ពិពាហ៍នឹងពេលណុងបងគិតថាបងសប្បាយដែរទេ?

ខ៖ ពេលណុងគិតសប្បាយដែរនឹងហាស
គិតថាសប្បាយពេលដែររៀងអាពាហ៍ពិពាហ៍ហើយគិតថា សប្បាយដែរនឹងហាស
ទោះចង់រកស៊ីអីក៏យើងគិតថាយើងមានប្រពន្ធយើងមានទឹកចិត្តដែរ

ក៖ ទោះយ៉ាងម៉េចក៏យើងអាចទៅជាមួយគាត់ដែរណបង?

ខ៖ បាទទៅបឹងទៅព្រៃក៏នឹកឃើញថាសប្បាយចិត្តដែរ

ក៖ ប៉ុន្តែសំរាប់កូនរបស់បងនឹងគាត់មានក្រុមគ្រួសារនៅបង?

ខ៖ គាត់មិនទាន់មានផងនឹង

ក៖ អូ!!ចុះសំរាប់នឹងបងមានកូនប៉ុន្មាននាក់ដែរទៅបង?

ខ៖ ខ្ញុំមានកូនចំនួន5នាក់

ក៖ បងមានកូន5នាក់ ចុះមានស្រីប៉ុន្មាននាក់នឹងប្រុសប៉ុន្មាននាក់ដែរទៅបង?

ខ៖ មានប្រុស3នាក់នឹងស្រី2នាក់នឹង

ក៖ អូៗ!!បាទបង
ចុះបងកាលពីក្មេងហាសបងធ្លាប់មានគោលបំណងថាពេលដែរធំឡើងនឹងបង
ចង់ធ្វើជាអីគេដែរទេបងធ្លាប់មានក្តីប្រាថ្នាអីទេ?

ខ៖ អត់អត់មានក្តីប្រាថ្នាអីធំដុំទេ

ក៖ លក្ខណះថាបងកាលពីនៅរៀនបងចង់ធ្វើជាគ្រូ រឺមួយក៏ចង់ធ្វើជាប៉ូលីស
រឺក៏ចង់ធ្វើជាពេទ្យអីបងធ្លាប់គិតពីមុនមកទេ?

ខ៖ អត់ធ្លាប់គិតទេបើអត់មានយើងអត់មាននិស្ស័យ មិនមែនថាអត់និស្ស័យទេ
យើងអត់បានរៀនបានសូត្រចេះដឹងចឹងយើងអត់ហ៊ានប្រាថ្នាខាងនឹងចឹង

ក៖ អូ!!បាទបងបាទនឹង?

ខ៖ បើយើងចេះដឹងទៅយើងអាចប្រាថ្នាចង់ធ្វើការងារធំអីបាន ចុះបើយើងអត់ចេះផងយើងមានអីប្រាថ្នាទៅចឹងអត់មានអីប្រាថ្នាទេ មានតែធម្មតាៗចឹងហាស

ក៖ អ៎ូ!!យើងធ្វើតាមធម្មតាទៅណាបង?

ខ៖ បាទយើងធ្វើតាមធម្មតាចឹងទៅណាស់

ក៖ រហូតទាល់តែយើងអាចខិតខំល្មមនឹងយើងអាចធ្វើបានប៉ុណ្ណឹងទៅណាបង?

ខ៖ បាទនឹងហើយធម្មតានឹង

ក៖ បាទបង ចុះបើសិនជាចង់អោយបងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗតើបងចង់ផ្តែផ្តាំអីទៅពួកគាត់ដែរបង?

ខ៖ ចង់ផ្តែផ្តាំអោយគាត់ខំប្រឹងរៀនសូត្រ ដល់ពេលចេះដឹងទៅរកការងារធំធ្វើល្អចឹងហាស

ក៖ បាទបងបាទ?

ខ៖ កុំអោយវាពិបាកដូចយើងពីមុនមកនឹងហាស យើងពិបាករកការងារធ្វើមិនបាន

ក៖ បាទបងបាទ?

ខ៖ ចុះយើងអត់បានរៀនបានសូត្រយើងពិបាកនឹង តែអត់ចេះនឹងគេមិនយកទេការងារសម័យឥឡូវនឹង

ក៖ ធម្មតាទាល់តែយើងរៀនចេះបានមានការងារល្អគួរសមមែនទេបង?

ខ៖ បាទបានមានការងារធ្វើ

ក៖ ចុះបើសិនជាចង់អោយពួកគាត់ជៀសវៀងវិញតើបងចង់អោយពួកគាត់ជៀសវៀងអីគេដែរបង?

ខ៖ ជៀសវៀងការល្បែង ការសេបគ្រឿងញៀនអីនឹង អោយជៀសវៀងអោយឆ្ងាយទៅនឹង

ក៖ ចឹងបងមានអីដែរចង់ផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗៗរបស់បងផ្សេងទៀតដែរទេបង ដូចថាអោយគាត់ខំប្រឹងនឹងអោយពួកគាត់អាចសំរេចនៅគោលបំណងរបស់បងចឹងហាសបង?

ខ៖ បាទមានតែអោយគាត់ខំប្រឹងរៀនសូត្រ
ខំប្រឹងរកការងារធ្វើអោយល្អៗបានធ្វើអីចឹងទៅ
ជៀសវៀងរឿងការរឿងគ្រឿងញៀនអីចឹងទៅ ធ្វើជាក្មេងគំរូក្មេងល្អអីចឹងទៅណាស់ ទៅអនាគត់ទៅមុខចឹងទៅ

ក៖ អូ៎!!បាទបងបាទនឹង?

ខ៖ នឹងហើយមានចឹង

ក៖ ចឹងមានអីដែរចង់ផ្ដែផ្ដាំអីផ្សេងៗៗទៀតទៅពួកគាត់ដែរទេបង?

ខ៖
មានតែប៉ុណ្ណឹងអស់ហើយនឹងមិនដឹងថាមានអីផ្ដែផ្ដាំទៀតផងនឹងហាសអោយពួកគាត់មានអនាគត់ល្អ

ក៖
ចឹងហោសបងចង់ផ្ដែផ្ដាំរឺប្រាប់ពួកគាត់អោយពួកគាត់ធ្វើអីមួយដែរល្អៗចឹងហោសបង?

ខ៖ នឹងហើយ

ក៖ អូ៎!!បាទបង ចឹងជាចុងក្រោយ?

ខ៖ មានតែប៉ុណ្ណឹងមានតែអោយគាត់ធ្វើល្អក្នុងការងាររៀនសូត្រអីនឹង
រកស៊ីអីមួយមានការងារធ្វើល្អ

ក៖ បាទបង ហើយនឹងអោយពួកគាត់អាចស្ដាប់ឪពុកម្ដាយបានចឹងទៅណបង?

ខ៖ នឹងហើយចឹង

ក៖
បាទបងបាទចឹងជាចុងក្រោយខ្ញុំអរគុណាច្រើនបងដែរបានអោយខ្ញុំបានពិភាក្សាជាមួយបងដែរទាក់ទងពីប្រវត្តិរបស់បង

ហើយការសំភាសន៍ទាំងអស់នេះខ្ញុំនឹងរៀបចំដាក់ក្នុងសកលវិទ្យាល័យដើម្បី
ទុកអោយបងវិញដើម្បីទុកអោយកូនចៅបានស្តាំនឹងបានដឹងចឹងហាសបង៕៕៕